**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣✵៥

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ១០២៤
ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩
សាលក្រមលេខ ១២ ៩៩
ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ០៩ ព្រឹក ដោយមានសមាសភាព ៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

### ដើមចោទ

ឈ្មោះ [redacted] **សេងលីម** ភេទស្រី កើតថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៨៦ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០២០៥១០៨៩៣ (០១) មានទីលំនៅ[redacted] ។

### អ្នកតំណាងដោយអាណត្តិ

លោក [redacted] ជាមេធាវី និងលោកស្រី [redacted] ជាមេធាវី។

មានការិយាល័យមេធាវី [redacted] មានអាសយដ្ឋានបន្ទប់ [redacted] ។

### ចុងចម្លើយ

ឈ្មោះ [redacted] **វណ្ណារិទ្ធិ** ភេទប្រុស ជនជាតិខ្មែរ កើតថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៨៦ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦១៤១០២១៣ មានទីលំនៅបច្ចុប្បន្ន[redacted]។

### អ្នកតំណាងដោយអាណត្តិ

ពុំមានអ្នកតំណាងដោយអាណត្តិ ។

## អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **វណ្ណារិទ្ធិ** សងប្រាក់ចំនួន ៧០.០០០ **(ប្រាំពីរម៉ឺន) ដុល្លារអាមេរិក** មកដើមចោទឈ្មោះ [redacted] **សេងលីម**។

២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **វណ្ណារិទ្ធិ** សងប្រាក់ចំនួន ១៧.០០០ **(មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក** ដែលជាតម្លៃនៃរថយន្តម៉ាកស្តារិច ០១ (មួយ) គ្រឿង និងម៉ូតូម៉ាកដ្រីមសង់ ០១ (មួយ) គ្រឿង ឱ្យមកដើមចោទឈ្មោះ [redacted] **សេងលីម**។

៣. សុំអនុវត្តជាបណ្ដោះអាសន្ននៅលើចំណុចទី១ និងទី២ ខាងលើ ។

៤.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

## ខ.ដំណើររឿងក្ដី និងចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្ដី

កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ឈ្មោះ [redacted] វណ្ណារិទ្ធិ បានខ្ចីប្រាក់ចំនួន ៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ឡានស្ការិច ០១ (មួយ) គ្រឿង ដែលមានតម្លៃ ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងម៉ូតូសង់ ០១ (មួយ) គ្រឿង តម្លៃ ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ដើម្បីយកទៅលក់ ហើយសន្យាថា សងវិញនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ប៉ុន្តែចុងចម្លើយពុំបានសងវិញទៅតាមកាលកំណត់នោះទេ រហូតមកដល់បច្ចុប្បន្នក៏ចុងចម្លើយមិនបានសងប្រាក់ និងប្រាក់ដែលជាតម្លៃតបរថយន្ត និងម៉ូតូ ត្រលប់មកវិញតាមកិច្ចសន្យាឡើង ដោយចុងចម្លើយមិនអនុវត្តកាតព្វកិច្ច ។

### ខ.២ អង្គហេតុដែលគ្មានចំណុចវិវាទ

ក្នុងរឿងក្ដីនេះ ដោយហេតុថា ចុងចម្លើយអវត្តមានក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងអវត្តមានក្នុងកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ហេតុដូច្នេះ ពុំមានអង្គហេតុដែលគ្មានវិវាទទេ ដែលបានអះអាងដោយដើមចោទ និងចុងចម្លើយឡើយ។

### ខ.៣ ចំណុចវិវាទ

តើការអះអាងរបស់ដើមចោទជាការពិតដែរឬទេ?

### ខ.៤ ការអះអាងរបស់ភាគីចំពោះចំណុចវិវាទ

#### ខ.៤.១ ការអះអាងរបស់ដើមចោទ

អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ និងដើមចោទឈ្មោះ [redacted] សេងលីម បានថ្លែងការណ៍ថា៖ ខ្លួនសុំរក្សាការខ្លឹមសារការទាមទារដូចនៅក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០១៩ និងសុំបន្ថែមការទាមទារចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០១០ របស់ខ្លួនដោយផ្អែកលើអង្គច្បាប់ដូចតទៅ៖

ក. យោងកិច្ចសន្យាចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ចុងចម្លើយឈ្មោះ [redacted] វណ្ណារិទ្ធិ បានខ្ចីប្រាក់ចំនួន ៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ម៉ូតូម៉ាកសង់មួយគ្រឿង និងរថយន្តម៉ាកស្ការិចមួយគ្រឿង ដែលម៉ូតូនិងរថយន្តនេះមានតម្លៃសរុបចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក។ សរុបជាទឹកប្រាក់ទាំងអស់ចំនួន ៨៧.០០០ (ប្រាំបីម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ហើយសន្យាថាសងបំណុលទាំងអស់ត្រឡប់មកវិញនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ប៉ុន្តែភាគីចុងចម្លើយឈ្មោះ [redacted] វណ្ណារិទ្ធិ ពុំបានអនុវត្តកាតព្វកិច្ចរបស់គាត់តាមកិច្ចសន្យាទេ។ ដោយកាលកំណត់ឱ្យអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ បានកន្លងផុត ហើយភាគីចុងចម្លើយក៏មិនព្រមអនុវត្តកាតព្វកិច្ច ហេតុនេះ ស្នើសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់ទាំងអស់ចំនួន ៨៧.០០០ (ប្រាំបីម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទវិញ យោងតាមមាត្រា ៥៩១ និងមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី។

ខ. ដោយសារតែដំណើរការនីតិវិធីនៅវែងឆ្ងាយទៅមុខទៀត ហើយត្រូវការប្រាក់ជាចាំបាច់ដើម្បីដោះបំណុលដែលបានជំពាក់គេដែរនោះ ហើយការទាមទារនេះគឺជាការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ផ្អែកតាមកិច្ចសន្យា ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ខ្លួនស្នើសុំឱ្យតុលាការប្រកាសថាសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន



Scanned with CamScanner

លើទំហំទឹកប្រាក់ដើម ដើម្បីឱ្យដើមចោទមានលទ្ធភាពទទួលបានប្រាក់ដើមរបស់គាត់មកវិញដោយឆាប់រហ័ស ហើយកាត់បន្ថយការខូចខាតរបស់ខ្លួន កុំឱ្យការខូចខាតរបស់គាត់ចេះតែរួសបន្លាយ និងកាន់តែធ្ងន់ធ្ងរ យោងតាមមាត្រា ១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

គ. ដោយសារតែការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយឈ្មោះ [redacted] វណ្ណារិទ្ធិ តាមកិច្ចសន្យាចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ធ្វើឱ្យដើមចោទត្រូវចំណាយលើប្រាក់ប្រដាប់ក្តីដែលគាត់មិនត្រូវចំណាយលើប្រាក់បប្រដាប់ក្តីនេះទាំងនេះទាល់តែសោះ បើភាគីចុងចម្លើយអនុវត្តកាតព្វកិច្ច តាមកិច្ចសន្យា ហេតុនេះ សុំឱ្យតុលាការសម្រេចឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីយោងមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ខ.៤.១ ការអះអាងរបស់ចុងម្លើយ**

ក្នុងរឿងក្តីនេះ ដោយហេតុថា ចុងចម្លើយអវត្តមានក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងអវត្តមានក្នុងការបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ក្រោយពេលទទួលបានដីកាកោះហៅ ដោយពុំមានមូលហេតុ ហេតុដូច្នេះ ពុំមានការអះអាងលើអង្គហេតុណាមួយដែលត្រូវធ្វើឡើងដោយចុងចម្លើយឡើយ។

## សំអាងហេតុ

១. យោងតាមកិច្ចសន្យាជំពាក់ប្រាក់ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ រវាងដើមចោទ និងចុងចម្លើយ ជាឯកសារភស្តុតាង ដែលអាចបញ្ជាក់បានថា ចុងចម្លើយបានខ្ចីប្រាក់ចំនួន ៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ម៉ូតូម៉ាកសង់មួយគ្រឿង រថយន្តម៉ាកស្តារិច មួយគ្រឿង និងបានកំណត់កាលបរិច្ឆេទនៃការសងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។ តុលាការយល់ឃើញថា កិច្ចសន្យាជំពាក់ប្រាក់ខាងលើ គឺជាប្រភេទនៃកិច្ចសន្យាខ្ចីបរិភោគ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី និងមានអានុភាពចំពោះគូភាគី គិតចាប់ពីកាលបរិច្ឆេទនៃការបង្កើតកិច្ចសន្យានេះ។

២.តាមពាក្យបណ្តឹងរបស់ដើមចោទ និងសេចក្តីថ្លែងការណ៍របស់ដើមចោទបានបញ្ជាក់ថា នៅពេលដល់កាលកំណត់សង ចុងម្លើយមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឲ្យស្របតាមមាត្រា ៥៩១ និងមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី។ ដូចនេះ តុលាការអាចជឿជាក់បានថា ការអះអាងរបស់ដើមចោទ មានមូលហេតុនៃការទាមទារផ្អែកលើកិច្ចសន្យាជំពាក់ប្រាក់ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ដែលជាភស្តុតាងបញ្ជាក់អំពីការទាមទារតាមកថាខណ្ឌទី២ នៃមាត្រា ២០១ នៃក្រមរដ្ឋប្បវេណី។

៣.យោងតាមពាក្យស្នើសុំបន្ថែមការទាមទារចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ដើមចោទបានស្នើសុំអនុវត្តជាបណ្តោះអាសន្ន ហើយតាមការអះអាងរបស់ដើមចោទ បានបញ្ជាក់ថា ដំណើរការនីតិវិធីអាចនៅវែងឆ្ងាយទៅមុខទៀត ហើយត្រូវការប្រាក់ជាចាំបាច់ដើម្បីដោះបំណុលដែលបានជំពាក់គេ ដើម្បីឱ្យដើមចោទមានលទ្ធភាពទទួលបានប្រាកដើមរបស់គាត់មកវិញឆាប់រហ័ស ហើយកាត់បន្ថយការខូចខាត ដើម្បីកុំឱ្យការខូចខាតរបស់ខ្លួនចេះតែរួសបន្លាយ និងកាន់តែធ្ងន់ធ្ងរ។ ដូចនេះ តុលាការ គប្បីសម្រេចតាមការស្នើសុំរបស់ដើមចោទ ស្របតាមបញ្ញត្តិមាត្រា ១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤. តាមមាត្រា ៦៤ កថាខណ្ឌទី១ (ភាគដែលត្រូវទទួលបន្ទុក និងការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) មាត្រា ៦៥ កថាខណ្ឌទី១ (ការសម្រេចសេចក្តីលើបន្ទុកនៃការបង់ប្រាក់ប្រដាប់ក្តី) និងមាត្រា ១៨២ កថាខណ្ឌទី៣ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងកំណត់អំពីបន្ទុកប្រាក់ប្រដាប់ក្តី ឲ្យជាបន្ទុករបស់ចុងចម្លើយ។



Scanned with CamScanner

# សេចក្តីសម្រេចបញ្ចប់

១.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] វណ្ណារិទ្ធិ សងប្រាក់ចំនួន ៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ឲ្យមកដើមចោទឈ្មោះ [redacted] សេងលីម ដោយផ្អែកលើកិច្ចសន្យាជំពាក់ប្រាក់ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩។

២.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] វណ្ណារិទ្ធិ សងប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរម៉ឺន) ដុល្លារអាមេរិក ដែលជាតម្លៃតបនៃរថយន្តម៉ាកស្តារិច ០៣គ្រឿង និងម៉ូតូម៉ាកដ្រីមសង់ ០១ (មួយ)គ្រឿង ឲ្យមកដើមចោទឈ្មោះ [redacted] សេងលីម ដោយផ្អែកលើកិច្ចសន្យាជំពាក់ប្រាក់ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩។

៣.ឲ្យអនុវត្តជាបណ្តោះអាសន្នទៅលើចំណុចទី១ និងទី២ ខាងលើ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៥.សាលក្រមនេះ ប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍នឹងសាលក្រមតាមការកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមសាលក្រមដើម

ថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

កណ្តាល, ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]